NSW HEALTH
July 2005
[DOH-7605]

KHMER

# ការធ្វើតេស្តសើស្បែកដើម្បីរកមើលរបេង

# Tuberculin Skin Test

## តើជំងឺរបេងជាអ្វី?

- របេង (TB) ជាជំងឺមួយបង្កឡើងដោយការឆ្លងបាក់តេរី *Mycobacterium tuberculosis* ។ របេងអាចធ្វើឲ្យខូចសួត ឬក៏ផ្នែកឯទៃទៀតនៃរាងកាយ ហើយបង្កឲ្យមានជំងឺធ្ងន់ធ្ងរ។

## តើអ្វីទៅជាការធ្វើតេស្តសើស្បែកដើម្បីរកមើលរបេង?

- ការធ្វើតេស្តសើស្បែកដើម្បីរកមើលរបេង (TST), ដែលគេហៅថា តេស្ត Mantoux ផងដែរនោះ , ត្រូវគេប្រើដើម្បីឆែកពិនិត្យមើល ថាតើលោកអ្នកមានឆ្លងរោគរបេងឬទេ។
- ការចាក់ថ្នាំបន្តិចធ្វើឡើងនៅផ្នែកក្រោមស្បែកតែបន្តិច ជាធម្មតា នៅលើកំភួនដៃឆ្វេង ហើយរយៈពេល ពី ៤៨ ទៅ ៧២ម៉ោងក្រោយមក គេនឹងធ្វើការពិនិត្យកន្លែងចាក់ថ្នាំនោះ ដើម្បីរកមើលប្រតិកម្ម (ដុំពក) ដែលអាចលេចឡើង។
- ដុំពកមួយអាចកើតឡើង បើសិនជាលោកអ្នកមានឆ្លងរោគរបេង ឬក៏មានចាក់ថ្នាំបង្ការ BCG ។  បើសិនជាមានដុំពកមួយលេចឡើងនោះ ដុំពកនោះនឹងបាត់ទៅវិញនៅពេលក្រោយមកទៀត។
- មនុស្សមួយចំនួនតូចនៅក្នុងសហគមន៍នឹងមានលទ្ធផលវិជ្ជមានទៅនឹងការធ្វើតេស្ត TST នេះ ប៉ុន្តែ **មនុស្សភាគច្រើន ដែលឆ្លងមេរោគរបេង មិនកើតជំងឺរបេងទេ។**

## មុនពេលលោកអ្នកធ្វើតេស្ត **TST:**

ជាការសំខាន់ណាស់ដែលលោកអ្នកប្រាប់ឲ្យគិលានុបដ្ឋាកដឹង បើសិនជាលោកអ្នក:

- មានមហារីកប្រភេទណាមួយ ដោយរួមទាំងមហារីកក្រពេញឬក៏ជំងឺ Hodgkin ផង។
- ប្រើថ្នាំព្យាបាលរោគដែលធ្វើឲ្យប៉ះពាល់ប្រព័ន្ធការពារខ្លួន។ ឧទាហរណ៍ ថ្នាំ Cortico-steroids (prednisone), cyclosporin ឬក៏ថ្នាំព្យាបាលតាមបែបគីមីសាស្ត្រ (ដើម្បីព្យាបាលមហារីក)
- មានឆ្លងរោគណាមួយនាពេលថ្មីៗ (នៅក្នុងពេលមួយខែកន្លងមកនេះ) ឧទាហរណ៍ គ្រុនផ្តាសាយ កញ្ជ្រឹល ឬក្អកមាន់
- បានទទួលថ្នាំបង្ការ (នៅក្នុងពេលមួយខែកន្លងមកនេះ) ទប់ទល់នឹងស្រទ្បាទែន កញ្ជ្រឹលនិងស្អូច ឬក៏អុតតូច
- មានមេរោគឬក៏ជំងឺអេដស៍
- ស្ថានភាពទាំងនេះអាចប៉ះពាល់ដល់ការបកស្រាយនិងការគ្រប់គ្រងការធ្វើតេស្ត TST ។

## ការថែទាំកន្លែងចាក់ថ្នាំធ្វើតេស្ត

- សូមកុំអេះកន្លែងចាក់ថ្នាំនេះ
- សូមកុំគ្របកន្លែងចាក់ថ្នាំ ដោយប្រើបង់ ឬក៏លាបថ្នាំក្រមួនឬក្រែម
- បើសិនជាមានពងកន្ទួល សូមកុំឆ្កឹះឲ្យបែក
- លោកអ្នកអាចបន្តសកម្មភាពធម្មតាទាំងអស់បាន ដោយរួមទាំងការធ្វើការងារ កីឡានិងការងូតទឹក។

## តើមានអ្វីកើតឡើងក្រោយពីការធ្វើតេស្តរួច?

- ក្រោយពីការធ្វើតេស្តរួច **លោកអ្នកត្រូវត្រឡប់ទៅមន្ទីរធ្វើតេស្តវិញ បន្ទាប់ពីធ្វើតេស្តហើយបាន ៤៨ទៅ ៧២ ម៉ោង** ដើម្បីឲ្យគេអាចពិនិត្យ និងធ្វើកំណត់ត្រាទុកនូវប្រតិកម្មណាមួយ ទៅនឹងការធ្វើតេស្តនេះ។
- មនុស្សខ្លះដែលមានប្រតិកម្មអវិជ្ជមានទៅនឹងការធ្វើតេស្ត TST អាចត្រូវការ ការធ្វើតេស្ត TST លើកទី២។

## ហេតុអ្វីបានជាត្រូវធ្វើតេស្តសើស្បែករកមើលរោគរបេងនេះសាឡើងវិញ?

- តេស្ត TST លើកដំបូងអាចបង្ហាញភាពអវិជ្ជមាន ដោយសារប្រតិកម្មទៅនឹងតេស្ត TST អាចសាបរលាប ឬក៏បាត់បង់ឥទ្ធិពល មួយរយៈកាលក្រោយមកទៀត។
- តេស្ត TST លើកទី២ (2-step TST) គឺធ្វើឡើងដើម្បីរំញោចប្រព័ន្ធការពារខ្លួនឲ្យបង្កើតប្រតិកម្មមួយ ដែលប្រហែលជាបានបាត់សាបរលាបទៅហើយនោះ។
- ប្រតិកម្មវិជ្ជមាននិងប្រតិកម្មអវិជ្ជមានដែលមិនត្រឹមត្រូវ អាចធ្វើឲ្យការសំរេចចិត្តទៅលើការវាយតម្លៃនិងការព្យាបាលបន្តបន្ទាប់ទៀត មានការលំបាក។ ការធ្វើតេស្ត TST លើកទី២អាចជួយបញ្ជាក់បំភ្លឺនូវស្ថានភាពមិនច្បាស់លាស់នេះ។

**បើលោកអ្នកមានការបារម្ភអ្វីស្តីអំពីការធ្វើតេស្តនេះ ក្រោយពីលោកអ្នកចាកចេញពីទីនេះ សូមទូរស័ព្ទទៅមន្ទីរពិនិត្យសួត**